ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកោះកុង**
សំណុំរឿងព្រហ្មទណ្ឌលេខ : ១៨៨
ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៦
សាលក្រមលេខ : ៦៣ "ខ"
ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកោះកុង**

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តកោះកុង នាថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៧ វេលាម៉ោង ២:៣០ នាទីរសៀល ដោយមានសមាសភាពដូចតទៅ៖

<u>ចៅក្រមជំនុំជម្រះ</u>
-លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តកោះកុង
<u>តំណាងអយ្យការ</u>
-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង
<u>ក្រឡាបញ្ជីសវនាការ</u>
-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

-<u>ដើម្បីជំនុំជម្រះលើ</u> សំណុំរឿងព្រហ្មទណ្ឌលេខ: ១៨៨ ចុះថ្ងៃទី ០៩-០៩-២០១៦ ដែលមានជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើតនៅសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុន គ្មាន ។

ត្រូវចោទពីបទ: បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសដែលតែងឲ្យផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

-<u>ដើមបណ្តឹងរដ្ឋប្បវេណី</u> ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិ ០៣ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ។

-<u>បានឃើញ:</u> ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: ០៣ ស.យ/១៧ ចុះថ្ងៃទី ១៤-១០-២០១៦ របស់ ចៅក្រមសាលាដំបូងខេត្តកោះកុង ។

-<u>បានឃើញ:</u> ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៥៩ ចុះថ្ងៃទី ១៧-១០-២០១៦ របស់លោកប្រធានសាលាដំបូងខេត្តកោះកុង ។

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:</u>

កាលពីថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១០ និង៤៥នាទីព្រឹក ឈ្មោះ [redacted] បានទូរស័ព្ទមកប្រាប់ឈ្មោះ [redacted] ថា ប្រពន្ធឈ្មោះ [redacted] ានទាក់ទងជាមួយប្តីរបស់ខ្លួន ដោយប្រពន្ធឈ្មោះ [redacted] បានទៅដេកជាមួយប្តីរបស់ខ្លួនឈ្មោះ [redacted] ជាច្រើនដងមកហើយ និងសុំឲ្យប្រពន្ធឈ្មោះ [redacted] កុំមកទាក់ទងប្តីរបស់ខ្លួនទៀត ។

Scanned by CamScanner

ហើយឈ្មោះ [redacted] នៅតែបន្តទូរស័ព្ទមកឈ្មោះ [redacted] និយាយបរិហារកេរ្តិ៍ពីប្រពន្ធរបស់ឈ្មោះ [redacted] ជាបន្តបន្ទាប់ ព្រមទាំងបានសរសេរតាមរយៈពត៌មានសង្គមហ្វេសប៊ុកទៀត និងធ្វើការសួរនាំឈ្មោះ [redacted] នៅក្នុងផ្សារថ្មីចាំយាម ស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ដោយសម្លេងខ្លាំងៗ ធ្វើឲ្យមានការភ្ញាក់ផ្អើលដល់សាធារណៈជន នៅក្នុងផ្សារមើលមកឈ្មោះ [redacted] ។ ក្រោយពីបានលឺ និងឃើញឈ្មោះ [redacted] ធ្វើសកម្មភាពបែបនេះ ឈ្មោះ [redacted] ក៏បានសួរនាំប្រពន្ធឈ្មោះ [redacted] ហើយឈ្មោះ [redacted] បានឆ្លើយថា ពុំប្រព្រឹត្តដូចដែរឈ្មោះ [redacted] បាននិយាយប្រាប់នោះទេ ។

## <u>នាពេលសវនាការ</u>

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៩ ម៉ោង១០,៤៥នាទីព្រឹក ឈ្មោះ [redacted] បានទូរស័ព្ទមកខ្លួន ដោយប្រាប់ថា ប្រយ័ត្នប្រពន្ធឯង កុំឲ្យទាក់ទងប្តីគាត់ទៀត ហើយឈ្មោះ [redacted] នេះតែងតែទូរស័ព្ទមកខ្លួនជាច្រើនដងដោយនិយាយដដែលៗ ថាប្រពន្ធខ្លួនទាក់ទងជាមួយប្តីគាត់ តែខ្លួនបានសួរប្រពន្ធខ្លួនរួចហើយ ដោយប្រពន្ធរបស់ខ្លួនបដិសេធថា មិនបានធ្វើអ្វីក្បត់ខ្លួននោះទេ គឺគ្រាន់តែស្គាល់គ្នាធម្មតាប៉ុណ្ណោះ ព្រោះឈ្មោះ [redacted] ដែលជាប្តីរបស់ឈ្មោះ [redacted] នេះជាអ្នករត់ម៉ូតូឌុប ។ ហើយឈ្មោះ [redacted] បាននិយាយ ប្រាប់ខ្លួនទៀតថា ពួកគេចង់ចេញទៅជួលផ្ទះដើម្បីនៅជាមួយគ្នា ។ ក្នុងរឿងនេះ ខ្លួនសំណូមពរសុំ តុលាការជួយរកយុត្តិធម៌ ប្រសិនបើប្រពន្ធរបស់ខ្លួនបានប្រព្រឹត្តអំពើផិតក្បត់បែបនេះមែន សូមតុលាការសម្រេចតាមច្បាប់ ។

-សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា: ឈ្មោះ [redacted] ជាអ្នករត់ ម៉ូតូឌុប នៅមុខកាស៊ីណូ ហើយខ្លួនឧស្សាហ៍ ជិះម៉ូតូគាត់ ចឹងហើយក៏ស្គាល់គ្នា ។ លុះដល់អំឡុងខែសីហា ឆ្នាំ២០១៩ ប្រពន្ធរបស់ [redacted] ឈ្មោះ [redacted] បានខមមិនជេរខ្លួន តាមហ្វេសបុក ដោយសរសេរថា "ឈ្មោះ [redacted] ធ្វើការនៅកាស៊ីណូទាក់ទងប្តីគេ ! ប្តីគេប្រាប់គេអស់ហើយ ថាប្តីគេឈប់ទាក់ទង លេងហ្វេសបុក ជាមួយខ្លួនហើយ !តែថាខ្លួននៅតែលេងជាមួយប្តីគេទៀត" ។ ក្រោយមកខ្លួនមិនដឹងថាឈ្មោះ [redacted] បានលេខប្តីរបស់ខ្លួនពីណាមកទេ ក៏ទូរស័ព្ទទៅប្រាប់ប្តីខ្លួន ដោយនិយាយពាក្យមិនល្អពីខ្លួនជាច្រើនប្រាប់ប្តីខ្លួន ។ ហើយក្រោយមកខ្លួនបានជួបឈ្មោះ [redacted] នៅក្នុងផ្សារថ្មី នៅភូមិចាំយាម ដោយឈ្មោះ [redacted] ហៅខ្លួនដោយសួរខ្លួនថា ឈ្មោះ [redacted] មែន? ខ្លួនឆ្លើយថា ចាំ ពេលនោះឈ្មោះ [redacted] បានចង្អុលមុខខ្លួន ដោយនិយាយលឺៗ ថា នាងឯងទាក់ទងប្តីគេ ខ្លួនតបវិញ ថា "កុំចោទខ្ញុំដល់ថ្នាក់នឹង ខ្ញុំគ្រាន់តែស្គាល់គ្នាតាមរយៈជិះម៉ូតូឌុប ទៅធ្វើការនៅកាស៊ីណូជាមួយគ្នា កុំនិយាយផ្តេសផ្តាស់" និងបាននិយាយទៀតថា "ខ្ញុំរវល់" រួចក៏បែកគ្នាទៅ ។ ក្រោយមកទៀត ឈ្មោះ [redacted] នៅតែបន្តនិយាយថាខ្លួនទាក់ទងប្តីគេរហូត ។ ខ្លួនសំណូមពរសុំតុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា: ខ្លួននិងឈ្មោះ [redacted] ពិតជាធ្លាប់មានទំនាក់ទំនងផ្លូវភេទជាមួយគ្នាមែន ។ កាលពីអំឡុងខែ០៣ រឺខែ០៤ ឆ្នាំ២០១៩ ខ្លួនបានស្គាល់ឈ្មោះ [redacted] ដោយខ្ញុំជាអ្នករត់ម៉ូតូឌុប រីឯឈ្មោះ [redacted] ជាម៉ូយម៉ូតូរបស់ខ្លួន ។ លុះស្គាល់គ្នាយូរទៅ ខ្លួននិងឈ្មោះ [redacted] ក៏មានទំនាក់ទំនងស៊ីជម្រៅជាមួយគ្នា ដោយខ្លួន និងឈ្មោះ [redacted] ធ្លាប់ទៅដេកជាមួយគ្នានៅផ្ទះសំណាក់ ។ លុះដល់អំឡុងខែ០៦ ឆ្នាំ២០១៩ ឈ្មោះ [redacted] បានជួលផ្ទះមួយនៅភូមិថ្មី ក្នុងតម្លៃ ១៩ ម៉ឺនរៀល ដើម្បីទុកជួបជាមួយខ្លួនពិតមែន ។ ហើយខ្លួនក៏ធ្លាប់ដឹងថាប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] បានទូរស័ព្ទទៅឈ្មោះ [redacted] អំពីទំនាក់ទំនងរវាងខ្លួននិងប្រពន្ធគាត់ដែរ ។ ហើយប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] មិនដែលរករឿងឡូឡា ដាក់ខ្លួន និងឈ្មោះ [redacted] នៅកន្លែងធ្វើការ រឺផ្សារណាឡើយ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ កាលពីអំឡុងឆ្នាំ២០១៨ ខ្លួនពិតជាបានទូរស័ព្ទទៅឈ្មោះ [redacted] ដោយបានប្រាប់ថាឈ្មោះ [redacted] ជា ប្រពន្ធរបស់គាត់ មានទំនាក់ទំនងជាមួយប្តីរបស់ខ្លួន និងឲ្យគាត់ប្រាប់ប្រពន្ធគាត់កុំឲ្យទាក់ទងជាមួយនិងប្តីរបស់ខ្លួនទៀតប្រាកដមែន ។ ក្រោយមកកាលពីអំឡុងឆ្នាំ ២០១៨ នោះដែរ ខ្លួនបានជួបឈ្មោះ [redacted] ត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] នៅផ្សារភូមិថ្មី ស្ថិតនៅក្នុងភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ពេលនោះ ខ្លួនបានសួរគាត់ថា "ហេតុអ្វីក៏នៅតែពាក់ព័ន្ធជាមួយគ្រួសារខ្ញុំអីចឹង?" ពេលនោះដែរឈ្មោះ [redacted] តបវិញថា "គាត់មិនបានពាក់ព័ន្ធអ្វីទៀតទេ" ។ នៅពេលដែលខ្លួនសួរគាត់នោះ គឺមានតែខ្លួននិងឈ្មោះ [redacted] តែប៉ុណ្ណោះ ពួកខ្លួននិយាយគ្នាមិនដល់ប្រាំនាទីផងក៏បែកគ្នា ។ ខ្លួននិងឈ្មោះ [redacted] និយាយគ្នាដោយធម្មតាទេ មិនមានការស្រែកឡូឡាផ្អើលដល់អ្នកណាទេ ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ នៅថ្ងៃកើតហេតុនោះខ្ញុំបានទៅផ្សារភូមិថ្មីជាមួយកូនស្រីឈ្មោះ [redacted] ដោយពេលនោះកូនស្រីរបស់ខ្លួនកំពុងឈរទិញឥវ៉ាន់ស្រាប់តែមានមនុស្សស្រីម្នាក់ បានហៅកូនស្រីខ្ញុំទៅនិយាយគ្នា ដោយខ្លួននៅចម្ងាយប្រហែលជា ២ ទៅ៣ម៉ែត្រ ពីពួកគេ ។ ខ្លួនបានលឺគេសួរកូនស្រីខ្លួនថាឈ្មោះ [redacted] រឺមិនមែន? កូនខ្លួនឆ្លើយថា "ចាស" ដោយឆ្លើយហើយ មនុស្សស្រីម្នាក់នោះបាននិយាយថា កុំឲ្យកូនខ្លួនទាក់ទងប្តីគេទៀត ដោយប្រើសម្លេងៗ ធ្វើឲ្យអ្នកនៅផ្សារងើលមើលមកគ្រប់គ្នា ។ ខ្លួននឹក ឃើញថា ពីមុនធ្លាប់មានមនុស្សស្រីម្នាក់បានរកមកខ្លួន ដោយនិយាយប្រាប់ខ្លួនថា កូនស្រីរបស់ខ្លួនបានទាក់ទងប្តីរបស់គេ ដោយបញ្ជាក់ថា មនុស្សនៅកន្លែងធ្វើការ អ្នកណាក៏គេនិយាយប្រាប់ចឹងដែរ តែខ្លួនប្រកែកដោយចាំខ្ញុំ សួរកូនរបស់ខ្លួនសិន ហើយពេលនោះខ្លួនបាននិយាយរឿងនេះជាមួយកូនប្រសារខ្លួន ទើបកូនប្រសារខ្ញុំមកដាក់ពាក្យបណ្តឹងព្រោះខ្លាចមានរឿងមិនល្អណាមួយកើតឡើងលើកូនស្រីរបស់ខ្លួន ព្រោះមនុស្សស្រីម្នាក់នោះកំពុងនឹងប្រចណ្ឌ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសថា៖ មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ពីបទ៖ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។ តាងនាមតំណាងអយ្យការ សូមរក្សាបទចោទប្រកាន់ទុកជាបានការពេញទាំងមូលដដែល និងស្នើសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីឈ្មោះ [redacted]
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សម្តី និងសំណូមពរចុងក្រោយបង្អស់របស់ជនជាប់ចោទ

<u>ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ</u>

<u>សាលាដំបូងខេត្តកោះកុង</u>

<u>យល់ឃើញថា៖</u>

-កាលពីថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង ១០,៤៥នាទី នៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ពិតជាមានអំពើ បរិហារកេរ្តិ៍ជាសាធារណៈប្រាកដមែន ហើយអំពើនេះត្រូវបានច្បាប់ចែងជាបទល្មើសព្រហ្មទណ្ឌ តាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។



Scanned by CamScanner

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់ជនរងគ្រោះបានឆ្លើយគ្រប់ដំណាក់កាលមានភាពស៊ីសង្វាក់គ្នា ដែលអាចឲ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] ពិតជាបានថតរូបសិច ជាមួយឈ្មោះ [redacted] និយាយតាមផ្សារកំពង់ចាម និយាយតាមហ្វេសប៊ុកថា ប្រពន្ធរបស់ឈ្មោះ [redacted] មានទំនាក់ទំនងស្នេហាជាមួយប្តីរបស់ខ្លួន។

-តាមការអះអាងរបស់ឈ្មោះ [redacted] ខ្លួននិងប្រពន្ធគោះប៉ះរស់នៅជាមួយគ្នាកំដោយ តែពួកខ្លួនតែងតែទំនាក់ទំនងគ្នារហូតតាមរយៈទូរស័ព្ទ និងជួបគ្នាថ្ងៃសម្រាកពីការងារ ។

-ចម្លើយនេះស៊ីចង្វាក់ទៅនឹងចម្លើយរបស់ឈ្មោះ [redacted] ដែលថាខ្លួនមិនដែលមានទំនាក់ទំនងស្នេហាជាមួយឈ្មោះ [redacted] ទេ ។

-អំពើរបស់ឈ្មោះ [redacted] មានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើស បរិហារកេរ្តិ៍ជាសាធារណៈ ដែលមានចែងក្នុងមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

-សេចក្តីសន្និដ្ឋានចោទប្រកាន់របស់តំណាងអយ្យការ សូមរក្សាការចោទប្រកាន់ និងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-សម្តីចុងក្រោយរបស់ជនជាប់ចោទ សូមឲ្យតុលាការវិនិច្ឆ័យតាមច្បាប់។

-សេចក្តីសន្និដ្ឋានចោទប្រកាន់របស់អយ្យការ និងសម្តីចុងក្រោយរបស់ជនជាប់ចោទ គប្បីតុលាការពិចារណា។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសាលាដំបូងខេត្តកោះកុង
## វិនិច្ឆ័យសេចក្តី

១/- ផ្តន្ទាទោសជនជាប់ចោទ ឈ្មោះ [redacted] ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ពិន័យជាប្រាក់ចំនួន ១.០០០.០០០ "មួយលាន"រៀល ពីបទៈ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

២/-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៧ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] បើកផ្លូវប្តឹងឧទ្ធរណ៍ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ហត្ថលេខា និងត្រា [redacted] ហត្ថលេខា និងត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
កោះកុង ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧
ក្រឡាបញ្ជី[illegible]

ចៅក្រមជំនុំជម្រះ

[redacted] [redacted]



Scanned by CamScanner